Seattle

EQUITY & ENVIRONMENT INITIATIVE

**មូលនិធិយុត្តិធម៌បរិស្ថានឆ្នាំ ២០២០**

កម្មវិធីទីក្រុងស៊ីអាថល។ គ្រប់គ្រងដោយមូលនិធិ Bullitt។

ឥឡូវនេះ**មូលនិធិយុត្តិធម៌បរិស្ថាន**កំពុងទទួលយកពាក្យសុំ ហើយ**ថ្ងៃផុតកំណត់ដើម្បីដាក់ពាក្យគឺថ្ងៃសុក្រទី 25 ខែកញ្ញា!** មានថវិកាចំនួន $500,000 ដុល្លារដែលអាចទទួលបានពីទីក្រុងស៊ីអាថល និងរហូតដល់ $60,000 ដុល្លារក្នុងមួយសំណើ។ ថវិកានេះគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងដែលដឹកនាំដោយ និងផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ខ្លាំងបំផុតពីបញ្ហាបរិស្ថាន និងអាកាសធាតុ ដូចជា៖ ជនជាតិស្បែកខ្មៅ ជនជាតិដើម ពលរដ្ឋគ្រប់ពណ៌សម្បុរ ជនអន្តោប្រវេសន៍ ជនភៀសខ្លួន ប្រជាពលរដ្ឋដែលមានប្រាក់ចំណូលទាប យុវជន និងមនុស្សចាស់ជរាដែលរស់នៅ រៀន ធ្វើការ លេង និងគោរពបូជានៅទីក្រុងស៊ីអាថល។

ការិយាល័យនិរន្តរភាពនិងបរិស្ថាន (The Office of Sustainability & Environment, OSE)

ដឹងថាជំងឺកូវីដ ១៩ (COVID-19)

កំពុងប៉ះពាល់ដល់សហគមន៍របស់យើងតាមមធ្យោបាយដែលយើងទើបតែចាប់ផ្តើមយល់។ ដោយសារហេតុផលនេះហើយដែលយើងស្វែងរកការផ្តល់មូលនិធិដល់គម្រោងនានាដែលដោះស្រាយផលប៉ះពាល់នៃជំងឺកូវីដ ១៩ (COVID-19) ដែលភ្ជាប់ទៅនឹងសុខភាពសហគមន៍ និងបរិស្ថាន។ OSE

នឹងរៀបចំវគ្គផ្តល់ព័ត៌មានតាមអ៊ីនធើណែតចំនួនពីរនៅ**ថ្ងៃទី 10 & 14 ខែកញ្ញា** ដើម្បីចែករំលែកនូវទិដ្ឋភាពទូទៅនៃមូលនិធិយុត្តិធម៌បរិស្ថាន គុណសម្បត្តិនៃការដាក់ពាក្យសុំដ៏រឹងមាំ ដំណើរការពិនិត្យ និងឆ្លើយសំនួរនានាដែលអ្នកអាចមាន។ សូមចូលមើលគេហទំព័រដើម្បីចុះឈ្មោះ និងស្វែងយល់បន្ថែម។ ប្រសិនបើអ្នកមានសំណួរ សូមផ្ញើអ៊ីម៉េល តាម equityenviro@seattle.gov ឬទូរស័ព្ទមកលេខ (206) 615-0817។